ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**កិច្ចព្រមព្រៀង**

**រវាង**

**រោងចក្រ ប៊ីយូធីហ្វូលវីនដូអេនធើប្រាយខេមបូឌា ខូអិលធីឌី**

**ជាមួយនិងតំណាងប្រតិភូបុគ្គលិក និងប្រធានក្រុម ប្រចាំរោងចក្រ**

នៅថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០២៣ វេលាម៉ោង ១១ ព្រឹក នៅក្នុងរោងចក្រ **យូធីហ្វូលវីនដូអេនធើប្រាយខេមបូឌា ខូអិលធីឌី**

មានកិច្ចប្រជុំមួយរវាងតំណាងក្រុមហ៊ុន និងតំណាងកម្មករនិយោជិត ។ នៅក្នុងកិច្ចប្រជុំនេះ នាយកក្រុមហ៊ុនបានជូនដំណឹងដល់កម្មករ និយោជិតទាំងអស់ស្តីពីស្ថានភាពបច្ចុបន្ននៃក្រុមហ៊ុន ដែលខ្វះអ្នកបញ្ជាទិញ ដែលបណ្តាលឲ្យសង្វាក់ផលិតកម្មត្រូវផ្អាកដំណើរការ ។ ហេតុដូចនេះក្រុមហ៊ុនសម្រេចចិត្តព្យួរកិច្ចសន្យា ការងាររបស់កម្មករនិយោជិតចំនួន ២២៥នាក់ (ស្រី ៩៤នាក់) ក្នុងចំណោមកម្មករនិយោជិតចំនួន១៦៧៥នាក់ (ស្រី៩៤៧នាក់) រយៈពេល ៥ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី ១៣ ខែមីនាឆ្នាំ២០២៣ ដល់ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ២០២៣ ។ ហើយក្នុងកំឡុងពេល ព្យួរការងារនេះកម្មករនិយោជិតបានឯកភាពទទួលយកការផ្តល់ជូនរបស់ក្រុមហ៊ុននូវប្រាក់ឈ្នួល១៩ដុល្លារសហរដ្ឋអាមេរិចរយៈក្នុងរយៈពេល៥ថ្ងៃ។

ប្រាក់ឧបត្ថម្ភក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងារនេះ និងបើកជូនបងប្អូនកម្មករនៅ មុនពេលកម្មករឈប់សម្រាកនៅថ្ងៃទី ១១ ខែ មីនា ឆ្នាំ២០២៣។ ចំពោះប្រាក់ឈប់សំរាក ប្រចាំឆ្នាំ ដែលនៅសល់ គឺក្រុមហ៊ុនបានទូទាត់ផ្តល់ជូនបងប្អូនកម្មករត្រឹមត្រូវរួចរាល់ស្របតាមច្បាប់ស្តីពីការងារ ដោយឡែក ប្រាក់បំណាច់ឆ្នាំ ៥%ក្រុមហ៊ុនក៏បានធ្វើការទូទាត់ជូនបងប្អូនកម្មកររួចរាល់ផងដែរ។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង១១ និង៤០ នាទី ព្រឹក នាថ្ងៃខែឆ្នាំដដែល ប្រកបដោយបរិយាកាសរីករាយ និងស្និតស្នាលក្រោមស្មារតីទទួលខុសត្រូវខ្ពស់ និងយោគយល់សហការគ្នាយ៉ាងរលូន។

ថ្ងៃសៅរ៍ ១៣កើត ខែ ផល្គុន ឆ្នាំ ខាល ចត្វាស័ក ពុទ្ធសករាជ ២៥៦៦

ស្វាយរៀង ថ្ងៃទី០៤ ខែ មីនា ឆ្នាំ ២០២៣

តំណាងក្រុមហ៊ុន

BEAUTIFUL WINDOW ENTERPRISE (CAMBODIA) CO., LTD.
KINGDOM OF CAMBODIA

ស្នាមមេដៃតំណាងកម្មករនិយោជិត
កិច្ចព្រមព្រៀង

រវាង

រោងចក្រ ប៊ីយូធីហ្វ៊ីលវីនដូអេនធើប្រាយខេមបូឌា ខូអិលធីឌី
ជាមួយនិងតំណាងប្រតិភូបុគ្គលិក និងប្រធានក្រុម ប្រចាំរោងចក្រ

១. ឈ្មោះ ...សោម សុវណ្ណារ៉ា... តួនាទី ...ប្រធានតំណាងកម្មករ...

២. ឈ្មោះ ...សំ គន្ធា... តួនាទី ...អនុប្រធាន...

៣. ឈ្មោះ ...សំ ទៅ ចរិយា... តួនាទី ...ប្រធានអាគារ...

៤. ឈ្មោះ ...ផាត ស្រី ណេង... តួនាទី ...ប្រធានផ្នែក...

៥. ឈ្មោះ ...សោម វាសនា... តួនាទី ...ប្រធានផ្នែក...

៦. ឈ្មោះ ...លាង ចិន្តាសុភ... តួនាទី ...ប្រធានអាគារ...

៧. ឈ្មោះ ...កើត ស្រីគា... តួនាទី ...ប្រធានក្រុម...

៨. ឈ្មោះ ...ជួ គន្ធវុឌ្ឍី... តួនាទី ...ប្រធានក្រុម...

៩. ឈ្មោះ ...ឋាយ រស្មី... តួនាទី ...ប្រធានក្រុម...